# <សេចក្ដីណែនាំសម្រាប់អ្នកប្រើប្រាស់សេវាប័ណ្ណថែទាំសុខភាពសម្រាប់មាតា-ទារកទើបកើត>

1. អ្នកប្រើប្រាស់សេវាដែលបានជូនដំណឹងអំពីសិទ្ធិទទួលបានប័ណ្ណទូទាត់ អ្នកត្រូវតែជ្រើសរើសទីភ្នាក់ងារផ្ដល់សេវាដោយផ្ទាល់ហើយចុះហត្ថលេខាលើកិច្ចសន្យា។
   - អ្នកប្រើប្រាស់ គឺអាចដាក់ពាក្យស្នើសុំសេវាកម្មដោយជ្រើសរើសភ្នាក់ងារផ្ដល់សេវា ដែលងាយស្រួលប្រើដោយមិនគិតពីអាសយដ្ឋានរបស់អ្នកប្រើប្រាស់។
     * ស្វែងរកទីភ្នាក់ងារផ្ដល់សេវាជូនតាមតំបន់៖ សេវាសង្គម ប័ណ្ណអេឡិចត្រូនិក(www.socialservice.or.kr)
   - ប្រសិនបើអ្នកមានហេតុផលសមស្រប អ្នកអាចស្នើសុំឱ្យផ្លាស់ប្ដូរទីភ្នាក់ងារផ្ដល់សេវា ឬបញ្ចប់កិច្ចសន្យាបច្ចុប្បន្នរបស់អ្នក បន្ទាប់មកចុះហត្ថលេខាលើកិច្ចសន្យាជាមួយទីភ្នាក់ងារផ្ដល់សេវាថ្មី។
2. អ្នកប្រើប្រាស់នៅពេលពិគ្រោះយោបល់ជាមួយភ្នាក់ងារផ្ដល់សេវា សូមប្រាប់ទៅភ្នាក់ងារផ្ដល់សេវាថាអ្នក គឺជាអ្នកប្រើប្រាស់ប័ណ្ណទូទាត់ដូច្នេះ អ្នកមិនត្រូវបានដកចេញពីការគាំទ្រពីរដ្ឋាភិបាលទេ។
3. អ្នកប្រើប្រាស់ត្រូវតែទូទាត់ប្រាក់ផ្ទាល់ខ្លួនតាមការកំណត់ទៅកាន់ទីភ្នាក់ងារផ្ដល់សេវាមុនពេលចាប់ផ្ដើមទទួលសេវាកម្ម។
4. ជាគោលការណ៍ រយៈពេលសុពលភាពនៃប័ណ្ណទូទាត់គឺក្នុងរយៈពេល60ថ្ងៃ គិតចាប់ពីថ្ងៃនៃការសម្រាលកូន។ សូមយកចិត្តទុកដាក់លើការកែតម្រូវពេលវេលាប្រើប្រាស់។
5. រយៈពេល និងពេលវេលានៃការប្រើប្រាស់ប័ណ្ណមានដូចខាងក្រោម។

| រយៈពេលនិងពេលវេលានៃសេវាកម្ម |
|---|
| - តាមគោលការណ៍ 5ថ្ងៃក្នុង1សប្ដាហ៍, 9ម៉ោងក្នុង1ថ្ងៃ (8ម៉ោង សម្រាប់បុគ្គលិកផ្ដល់សេវាកម្ម2នាក់) (រួមទាំងម៉ោងសម្រាក 1ម៉ោង)<br>* (ឱ) 09:00~18:00 (ពេលសម្រាក 12:00~13:00)<br>* ពេលអាហារថ្ងៃត្រង់ផ្សេងៗអាចប្រើជាពេលសម្រាកបាន ហើយអាហារគឺម្ដាយទារកជាអ្នកផ្ដល់អោយបុគ្គលិក<br>- គោលការណ៍ថ្ងៃឈប់សម្រាក គឺថ្ងៃសៅរ៍ និងថ្ងៃបុណ្យជាតិ (ថ្ងៃអាទិត្យ, ថ្ងៃប្រារព្ធបុណ្យជាតិ, បុណ្យប្រពៃណីជាតិ។ល។)<br>- ក្នុងករណីដែលជៀសមិនរួចក្នុងការកំណត់ថ្ងៃ និងពេលវេលានៃការផ្ដល់សេវាខុសពីគោលការណ៍ ដោយសារកាលៈទេសៈរបស់អ្នកប្រើប្រាស់ នោះអ្នកអាចកែតម្រូវបានតាមរយៈការពិគ្រោះយោបល់ជាមួយអ្នកផ្ដល់សេវា (គួរមានចែងក្នុងកិច្ចសន្យា)<br>- ទោះយ៉ាងណាក៏ដោយ ក្នុងករណីចន្លោះម៉ោង 22:00 ដល់ 07:00ព្រឹក សេវាប័ណ្ណទូទាត់មិនអាចផ្ដល់ជូនបានទេ |

6. អាស្រ័យលើប្រភេទនៃទារកនិងលំដាប់នៃកំណើតរយៈពេលសេវាក៏ខុសគ្នាដែរ។ អ្នកប្រើប្រាស់អាចជ្រើសរើសមួយ រវាងការកាត់បន្ថយ ស្តង់ដារ ឬការបន្ថែមរយៈពេល នៃប្រភេទដែលត្រូវនឹងសេវាកម្ម របស់អ្នកប្រើប្រាស់។
   - អាស្រ័យលើរយៈពេលសេវាកម្មដែលបានជ្រើសរើស ការឧបត្ថម្ភធនរបស់រដ្ឋាភិបាលត្រូវបានផ្ដល់ជូនខុសៗគ្នា ដូច្នេះសូមពិនិត្យមើលថ្លៃបង់ប្រាក់ផ្ទាល់ខ្លួនរបស់អ្នក។

ជ្រើសរើសរយៈពេលនៃសេវាកម្ម(ផលិតផល)

| ប្រភេទនៃការទ្រទ្រង់ | | រយៈពេលនៃសេវាកម្ម | | |
|---|---|---|---|---|
| | | ការកាត់បន្ថយ | ស្តង់ដារ | ការបន្ថែម |
| កូនមួយ | កូនដំបូង | 5ថ្ងៃ | 10ថ្ងៃ | 15ថ្ងៃ |
| | កូនទីពីរ | 10ថ្ងៃ | 15ថ្ងៃ | 20ថ្ងៃ |
| | កូនទីបីឡើង | 10ថ្ងៃ | 15ថ្ងៃ | 20ថ្ងៃ |
| សម្រាលកូនភ្លោះ | បុគ្គលិក 1នាក់ | 10ថ្ងៃ | 15ថ្ងៃ | 20ថ្ងៃ |
| | បុគ្គលិក 2នាក់ | 10ថ្ងៃ | 15ថ្ងៃ | 20ថ្ងៃ |
| កូនភ្លោះបីឬច្រើនជាងនេះ | បុគ្គលិក 2នាក់ | 15ថ្ងៃ | 20ថ្ងៃ | 25ថ្ងៃ |

* លំដាប់សម្រាលកូន គឺមិនផ្អែកលើចំនួនដងដែលម្ដាយសម្រាលទេប៉ុន្តែសំដៅទៅលើលំដាប់ឬលេខរៀងកូននៅក្នុងគ្រួសារ ដូចជាកូន ទីមួយ ទីពីរ និង ទីបី។
* ក្នុងករណីដែលម្ដាយមានពិការភាពធ្ងន់ធ្ងរ ប្រភេទB គឺសមរម្យសម្រាប់ការសម្រាលកូនតែមួយ ហើយប្រភេទC គឺសមរម្យសម្រាប់ការសម្រាល កូនភ្លោះចាប់ពីនាក់ឡើង។

- អ្នកប្រើប្រាស់ចុះហត្ថលេខាលើកិច្ចសន្យាប្រើប្រាស់ជាមួយភ្នាក់ងារផ្តល់សេវា ហើយអ្នកផ្តល់សេវា ចុះឈ្មោះមាតិកានោះលើប្រព័ន្ធប័ណ្ណទូទាត់អេឡិចត្រូនិកនៃសេវាសង្គម ហើយបន្ទាប់ពីប័ណ្ណទូទាត់ត្រូវបានបង្កើតឡើង រយៈពេលនៃសេវាកម្ម ដែលបានជ្រើសរើស (ផលិតផល) មិនអាចផ្លាស់ប្តូរបានទេ ដូច្នេះសូមអ្នកប្រើប្រាស់ជ្រើសរើសដោយប្រុងប្រយ័ត្ន។

7. សេវាកម្មស្តង់ដារដែលផ្តល់ដោយប័ណ្ណទូទាត់របស់រដ្ឋាភិបាលមានដូចខាងក្រោម។
   - អ្នកប្រើប្រាស់ដែលត្រូវការសេវាកម្មបន្ថែមលើសពីសេវាកម្មស្តង់ដារត្រូវចំណាយផ្ទាល់ខ្លួនបន្ថែម។

| សេវាកម្មសម្រាប់មាតា | សេវាកម្មមិនរួមបញ្ចូលនៅក្នុងសេវាកម្មស្តង់ដារ<br>(ឧទាហរណ៍ សេវាកម្មបន្ថែម) |
|---|---|
| - ការត្រួតពិនិត្យអំពីស្ថានភាពរាងកាយរបស់មាតា<br>- ការថែទាំសុដន់, ការត្រួតពិនិត្យការហើមក្រោយឆ្លងទន្លេ និងទ្រទ្រង់កាយសម្បទាក្រោយសម្រាល<br>- ការត្រួតពិនិត្យអាហារូបត្ថម្ភរបស់មាតា និងការរៀបចំអាហារ<br>- ទ្រទ្រង់នៅពេលត្រាំ(ស្អំ)គូទ, ការត្រួតពិនិត្យអនាម័យមាតា<br>- ការអប់រំមាតាទាក់ទងនឹងការបំបៅកូនដោយទឹកដោះម្តាយ, ការស្តារឡើងវិញក្រោយ សម្រាល និងការថែទាំទារកទើបនឹងកើត<br>- ការជួបប្រទះ និងដោះស្រាយនូវស្ថានភាពនៅពេលមានអាសន្ន<br>- ការសម្អាតកន្លែងរស់នៅរបស់មាតា·ទារកទើបនឹងកើត<br>- ការបោកគក់សម្លៀកបំពាក់របស់មាតា·ទារកទើបនឹងកើត ។ល។<br>- ការប្រឹក្សា និង ការនិយាយជាមួយអ្នកជិតស្និទ្ធ | ● ការសម្អាតក្រៅពីកន្លែងរស់នៅរបស់ មាតា·ទារកទើបនឹងកើត<br>- បន្ទប់គ្រួសារ ដទៃទៀត • បន្ទប់ទឹក និងកន្លែងប្រើប្រាស់រួម (ច្រកចូល, បន្ទប់ដាក់សៀវភៅ, បន្ទប់ដាក់សម្លៀកបំពាក់, រានហាល, ឃ្លាំង, បង្អួចកញ្ចក់, ទីធ្លាផ្ទះ។ល។), កន្លែងដាក់អីវ៉ាន់(កន្លែងលាងចាន,ទូទឹកកក, ទូខោអាវ, ទូដាក់ចាន, ទូដាក់ស្បែកជើង។ល។) ការសម្អាតផ្ទះទាំងមូលផ្សេងៗទៀត ដែលមិនមែនជាការសម្អាតរៀងរាល់ថ្ងៃ។<br>● ការបោកគក់ផ្សេងៗទៀត ក្រៅពីសម្លៀកបំពាក់របស់មាតា·ទារកទើបនឹងកើត<br>- ការបោកគក់សម្លៀកបំពាក់គ្រួសារផ្សេងទៀត, សម្លៀកបំពាក់តម្លៃថ្លៃៗ, ការបោកគក់ ប្រភេទខ្នាតធំៗ(ពូក, វាំងនន, ប្រភេទស្បែកជើង, ប្រភេទកាបូប, សម្លៀកបំពាក់តាមរដូវកាលទំហំធំ និងបោកគក់សម្លៀកបំពាក់ចាស់ៗ។ល។) |
| សេវាកម្មសម្រាប់ទារកទើបនឹងកើត | |
| - ការពិនិត្យសុខភាពទារកទើបនឹងកើត<br>- ការគ្រប់គ្រងអនាម័យទារកទើបនឹងកើត<br>- ការទ្រទ្រង់អំពីការបំបៅកូនដោយទឹកដោះម្តាយ សម្រាប់ទារកទើបនឹងកើត<br>- ការថែទាំអនាម័យទារកទើបនឹងកើត<br>- ការទ្រទ្រង់ការចាក់ថ្នាំបង្ការ<br>- ការការពារ និង ការថែទាំការឆ្លងមេរោគ<br>- ការជួបប្រទះ និងដោះស្រាយនូវស្ថានភាពនៅពេលមានភាពអាសន្ន | ● ការរៀបចំអាហារសម្រាប់សមាជិកគ្រួសារ·ញាតិមិត្ត ក្រៅពីមាតានិងទារកទើបនឹងកើត, ការរៀបចំអាហារនៅទីកន្លែងផ្សេង ក្រៅពីនៅផ្ទះ, អាហារជប់លៀង, អាហារដែលរក្សាទុក (គីមឈី·គ្រឿងទេស·ជ្រក់។ល។), ការទទួលភ្ញៀវ លើសពីកម្រិតនៃការបម្រើទឹកតែ<br>● ផ្សេងៗ<br>- ការផ្លាស់ទីគ្រឿងសង្ហារឹម / វត្ថុ ដែលទំហំធំ ឬធ្ងន់<br>- ការមើលថែកូនធំ ឬសមាជិកគ្រួសារផ្សេងទៀត។<br>- ការបើកបរជំនួស<br>- ការមើលថែសត្វចិញ្ចឹម ជាដើម។ |

8. អ្នកប្រើប្រាស់ និងបុគ្គលិក គឺត្រូវតែគោរព និងជឿជាក់លើបុគ្គលិកលក្ខណៈរបស់គ្នាទៅវិញទៅមក និងសូមអនុវត្តតាមចំណុចខាងក្រោម ដើម្បីទទួលបានសេវាកម្មនិងការផ្តល់សេវាកម្មកាន់តែប្រសើរ។

| ចំណុចដែលអ្នកប្រើប្រាស់ត្រូវគោរពតាម |
|---|

① អ្នកប្រើប្រាស់ ត្រូវតែគោរពបុគ្គលិកលក្ខណៈ និងវិជ្ជាជីវៈ របស់បុគ្គលិក។
② អ្នកប្រើប្រាស់ ត្រូវតែស្នើសុំសេវាកម្មក្នុងវិសាលភាពនៃស្តង់ដារសេវាកម្ម និងខ្លឹមសារនៃកិច្ចសន្យា។
※ សេវាកម្មបន្ថែម ដូចជាការមើលថែ·ការថែរក្សាគេហដ្ឋានសម្រាប់សមាជិកគ្រួសារក្រៅពីមាតា និងទារកទើបនឹងកើត មិនត្រូវបានរាប់បញ្ចូលក្នុងសេវាកម្មស្តង់ដារប័ណ្ណទូទាត់នេះទេ ហើយអាចស្នើសុំបានតែនៅពេលដែលសេវាកម្មបន្ថែមត្រូវបានជួលប៉ុណ្ណោះ□

③ នៅពេលអ្នកប្រើប្រាស់ស្នើសុំសេវាកម្មពីអ្នកផ្តល់សេវា សំណើត្រូវតែច្បាស់លាស់ ជាក់លាក់ និងគួរសម។

④ សូមហៅបុគ្គលិក(អ្នកថែទាំ។ល។) ជាផ្លូវការ។

⑤ អ្នកមិនត្រូវបញ្ចេញមតិ ឬសកម្មភាពមិនសមរម្យ ដាក់បុគ្គលិក ដូចជាប្រើពាក្យប្រមាថមើលងាយ ឬអំពើហិង្សាលើរាងកាយ។

※ ប្រសិនបើអ្នកប្រើអំពើហិង្សាលើរាងកាយ ដូចជាការវាយដំ អ្នកអាចនឹងត្រូវទទួលទោសទណ្ឌរដ្ឋប្បវេណី·ព្រហ្មទណ្ឌ ក៏ដូចជាបញ្ឈប់ការប្រើប្រាស់សេវាកម្មផងដែរ។

<ប្រភេទនៃអំពើហិង្សាដោយពាក្យសំដីនិងលើរាងកាយ>

- អំពើហិង្សាដោយពាក្យសំដី) ពាក្យប្រមាថ(ជេរ), ការគំរាមកំហែង, ការបំភិតបំភ័យ ។ល។
  * "យ៉ា.", "អអ៊ី." ។ល។ វាអាចនឹងស្តាប់ឮ ដូចជាពាក្យដែលមិនគោរព និងបុគ្គលិកលក្ខណៈ។
- អំពើហិង្សាលើរាងកាយ) ធ្វើសកម្មភាព កម្រិតគ្រោះថ្នាក់ដល់អាយុជីវិត ដូចជារុញច្រាន, ចាប់ក្របួចកអាវ, តាមចាប់, ទះកំផ្លៀង, ខាំ, ស្តោះទឹកមាត់ដាក់, ច្របាច់ក, បោះឬគប់របស់របរ, ដាល់ដោយកណ្តាប់ដៃ ឬទាត់ដោយជើង, សំដៅលើកាំបិត, ចាក់ ។ល។

⑥ អ្នកមិនត្រូវប្រព្រឹត្តអំពើដែលពាក់ព័ន្ធនឹងអំពើបៀតបៀនផ្លូវភេទ ឬអំពើហិង្សាផ្លូវភេទ ដែលបណ្តាលឱ្យមានការអាម៉ាស់ផ្លូវភេទដល់បុគ្គលិកផ្តល់សេវានោះទេ។ ជាពិសេស ទោះបីជាធ្វើទង្វើដែលបង្កភាពមិនស្រួលដោយការប៉ះពាល់រាងកាយដែលមិនចាំបាច់ ឬការអាក្រាតកាយ, ការនិយាយលេងសើចប៉ះពាល់នឹងផ្លូវភេទជាដើម ក៏ស្ថិតនៅក្រោមការបៀតបៀនផ្លូវភេទផងដែរ។

※ ករណីត្រូវបានបំភ្លឺថាអ្នកប្រើប្រាស់ ឬគ្រួសាររបស់អ្នកប្រើប្រាស់មានធ្វើទង្វើការបៀតបៀនផ្លូវភេទ ទៅលើបុគ្គលិកដែលផ្តល់ជូននោះអាចបដិសេធមិនផ្តល់សេវាកម្មបាន ហើយអាស្រ័យលើភាពធ្ងន់ធ្ងរ អ្នកប្រើប្រាស់អាចនឹងត្រូវបានដកហូតសិទ្ធិ ពីការប្រើប្រាស់សេវាកម្ម ឬត្រូវផ្តន្ទាទោសក្រោម「 ច្បាប់ពិសេសស្តីពីការដាក់ទណ្ឌកម្មផ្សេងៗនៃឧក្រិដ្ឋកម្មហិង្សាផ្លូវភេទ」។

<ប្រភេទនៃការបៀតបៀនផ្លូវភេទអំពើហិង្សាផ្លូវភេទ>

- (ការបៀតបៀនផ្លូវភេទដោយការមើល) ដូចជារូបថត·ការបោះពុម្ពផ្សាយ រូបអាសអាភាស, កាយវិការដោយផ្លូវភេទ ការបញ្ចេញរាងកាយហួសហេតុ
- (ការបៀតបៀនផ្លូវភេទដោយពាក្យសំដី) ដូចជាប្រើពាក្យអាសអាភាស, ការអត្ថាធិប្បាយឬនិយាយលេងការនិយាយលេងសើចដែលបង្ហាញពីសកម្មភាពផ្លូវភេទ
- (ការបៀតបៀនផ្លូវកាយ) ការប៉ះពាល់នឹងផ្លូវភេទ, ការឱប, ការបបោសអង្អែល, ការរំលោភបំពាន, ការចាប់រំលោភ
- (ផ្សេងៗ) ការប្រើភាសាឬអាកប្បកិរិយា ដែលអាចបណ្តាលឱ្យមានការអាម៉ាស់ ឬស្អប់ខ្ពើមតាមបទដ្ឋានសង្គម ដូចជាការបង្ហាញរូបអាសអាភាស ឬណែនាំឱ្យមើលជាមួយគ្នា, ការបង្ខំណាត់ជួបដើរលេង ឬសេពគប់គ្នា, សំណើឱ្យបម្រើកន្លែងផឹកស្រា ។ល។

⑦ សូមគោរពពេលវេលាចាប់ផ្តើម និងបញ្ចប់ដូចមានចែងក្នុងកិច្ចសន្យា ហើយត្រូវតែផ្តល់ពេលវេលាសម្រាក (1ម៉ោងក្នុង1ថ្ងៃ) ដល់បុគ្គលិកសេវាកម្ម ដោយអាចឈប់សម្រាក ចេញពីកន្លែង ឬពីការងារដោយសេរី។

ការសាកសួរទាក់ទងនឹងការប្រើប្រាស់សេវាកម្ម ស្ថាប័នផ្តល់សេវា○○○ (ទូរស័ព្ទ 000-0000, គេហទំព័រ www.abc.co.kr)